ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខៈ ៤០

ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩

សាលដីកា

លេខៈ ៥១ "I"

ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០

ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រមរបាយការណ៍

៤.លោក [redacted] ចៅក្រម

៥.លោកស្រី [redacted] ចៅក្រម

### ក្រឡាបញ្ជីសវនាការ

លោក [redacted]

### តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

### ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ៤៥២ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សិទ្ធិសក្តិ ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១០២ ក្រIIប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន ៖

-ជនជាប់ចោទឈ្មោះ [redacted] សិទ្ធិសក្តិ ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ មុខរបរ មន្ត្រីរាជការ ទីលំនៅបច្ចុប្បន្ននៅក្នុង [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] ទោសពីមុនគ្មាន (ក្រៅឃុំ) ។ (អ្នកប្តឹងសាទុក្ខ)

Scanned with CamScanner

លោក [redacted] រ៉ាដា ជាមេធាវីការពារសិទ្ធិ ។

**ជាប់ចោទពីបទ ៖** ហិង្សាដោយចេតនា និងចែកចាយរូបភាពអាសអាភាស ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ មាត្រា ៣៨ និងមាត្រា ៣៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

**ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] ចិន្តា ភេទស្រី អាយុ២៥ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted] រាជធានីភ្នំពេញ ។

**អំពីអង្គហេតុ ៖**

នៅអំឡុងខែមេសា ឆ្នាំ២០១៥ ឈ្មោះ [redacted] សិទ្ធិសក្តិ ភេទប្រុស អាយុ២៦ឆ្នាំ បានស្គាល់ឈ្មោះ [redacted] ចិន្តា ភេទស្រី អាយុ២៥ឆ្នាំ តាមរយៈសារអេឡិចត្រូនិច (Facebook) ហើយក៏មានទំនាក់ទំនង និងស្រឡាញ់គ្នា ដោយឈ្មោះ [redacted] សិទ្ធិសក្តិ បាននិយាយលួងលោមថានឹងយកឈ្មោះ [redacted] ចិន្តា ធ្វើជាប្រពន្ធស្របច្បាប់ និងរស់នៅជាមួយគ្នា បានមួយរយៈ ក្រោយមកឈ្មោះ [redacted] ចិន្តា និងឈ្មោះ [redacted] សិទ្ធិសក្តិ មានទំនាស់នឹងគ្នា ។ មកដល់ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ២២ និង ៣០នាទី ខណៈពេលដែលកំពុងជិះរថយន្តជាមួយគ្នា ឈ្មោះ [redacted] សិទ្ធិសក្តិ បានវាយឈ្មោះ [redacted] ចិន្តា បណ្តាលឱ្យរងរបួសជាំផ្ទៃមុខ ហើយឈ្មោះ [redacted] ចិន្តា ក៏ផ្តាច់ទំនាក់ទំនងជាមួយគ្នា [redacted] សិទ្ធិសក្តិ តែម្តង ។ ប៉ុន្តែឈ្មោះ [redacted] សិទ្ធិសក្តិ តែងតែផ្ញើសារគម្រាមក្នុងន័យធ្វើឱ្យឈ្មោះ [redacted] ចិន្តា អាម៉ាស់ និងបាត់មុខពីអាជីពសិល្បៈ ចូលក្នុងគណនីហ្វេសប៊ុក (Facebook) របស់ឈ្មោះ [redacted] ចិន្តា ។ មកដល់ខែមេសា ឆ្នាំ២០១៦ ឈ្មោះ [redacted] ចិន្តា បានទទួលព័ត៌មានពីមិត្តភក្តិជាច្រើននាក់ដោយនិយាយថា មានគេផ្ញើរូបភាពអាក្រាតកាយរបស់ខ្លួន (ឈ្មោះ [redacted] ចិន្តា) ចូលក្នុងគណនីរបស់ពួកគេ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២១០៥ "ឆ" ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ផ្តន្ទាទោសឈ្មោះ [redacted] សិទ្ធិសក្តិ ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់សរុប ០១ (មួយ)ឆ្នាំ ពីបទ ហិង្សាដោយចេតនា និងចែកចាយរូបភាពអាសអាភាស ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ និងមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ មាត្រា ៣៨ និងមាត្រា ៣៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

២.បង្គាប់ឱ្យឈ្មោះ [redacted] សិទ្ធិសក្តិ សងសំណងជម្ងឺចិត្តចំនួន ២០០.០០០.០០០(ពីររយលាន)រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សុខ ចិន្តា ការទាមទារលើសពីនេះត្រូវបដិសេធចោល ។

Scanned with CamScanner

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៧ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សិទ្ធិសក្តិ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិន្តា និងចំពោះមុខលោកមេធាវី [redacted] ពិសី ជាមេធាវីការពារសិទ្ធិជនជាប់ចោទ និងលោកមេធាវី [redacted] បូរ៉ា និងលោកមេធាវី [redacted] សុខចាន់ ជាមេធាវីការពារសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧ ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៨០៤ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] សិទ្ធិសក្តិ ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ២១០៥ "ឆ" ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ១០២ ក្រIIប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ទទួលបណ្តឹងឧទ្ធរណ៍លេខ ៨០៤ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] សិទ្ធិសក្តិ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២១០៥ "ឆ" ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣.សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ មេធាវីការពារសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ។

បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ៤៥២ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សិទ្ធិសក្តិ ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ១០២ ក្រIIប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានសុំថា ៖

Scanned with CamScanner

-យល់ឃើញថា តាមតុលាការអង្គសេចក្តីបញ្ជាក់ថា រូបភាពជនរងគ្រោះអាក្រាតកាយក្នុងបណ្តាញសង្គមដែលខ្លួនឯងជាអ្នកថា បែរជាថាជនរងគ្រោះជាអ្នកថត ហើយបង្ហោះក្នុងបណ្តាញសង្គម ។ ការដោះសារបៀបនេះ មិនត្រឹមត្រូវទេ ។

ដូចនេះ តំណាងមហាអយ្យការអមតុលាការកំពូល ឃើញថា ការយល់ឃើញរបស់តុលាការអង្គសេចក្តីគឺមានសំអាងហេតុច្បាស់លាស់ ។

ហេតុដូច្នេះ

តំណាងមហាអយ្យការប្តឹងសុំចំពោះតុលាការកំពូលឱ្យ

១.ទទួលបណ្តឹងសាទុក្ខលេខ ៤៥២ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សិទ្ធិសក្តិ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយខុសទៅនឹងគតិច្បាប់ ។

២.តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១០២ "ក្រ.II.ប" ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

+ជនជាប់ចោទឈ្មោះ [redacted] សិទ្ធិសក្តិ បានឆ្លើយថា ៖ ខ្ញុំអាយុ២៨ឆ្នាំ មុខរបរមន្ត្រីរាជការ ឪពុកស្លាប់ ហើយម្តាយនៅរស់ មានប្រពន្ធ ខ្ញុំបាទប្តឹងសាទុក្ខមកនេះ គឺខ្ញុំមិនបានប្រព្រឹត្តទេ ខ្ញុំគ្មានអំពើហិង្សាទេ គ្រាន់តែជំលោះពាក្យសម្តីគ្នា ចំណែករូបភាពជាំភ្នែក ខ្ញុំមិនដឹងគេយកមកពីណាទេ ។

មូលហេតុបង្ហោះរូបអាសអាភាស ខ្ញុំអត់បានដឹងទេ ខ្ញុំមានអាខោនតែ១គឺឈ្មោះ [redacted] សិទ្ធិសក្តិ ខ្ញុំមានការទំនាក់ទំនងរបៀបសង្សាជ្រាលជ្រៅ ខ្ញុំសុំបដិសេធ រឿងនេះខ្ញុំអត់បានដឹងទេ ។

សំណូមពរ ៖ ខ្ញុំមិនបានប្រព្រឹត្ត មេត្តាសម្រេចឱ្យខ្ញុំបាទរួចផុតពីបទចោទ ។

+លោក [redacted] ដារ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សិទ្ធិសក្តិ បានធ្វើសេចក្តីសន្និដ្ឋានថា ៖ ក្នុងរឿងនេះ កូនក្តីខ្ញុំបានបដិសេធហើយថា គាត់មិនបានប្រព្រឹត្តទេ បើពិនិត្យមើលក្នុងសំណុំរឿងគ្មានសាក្សី គ្មានភស្តុតាងច្បាស់លាស់ទេ ព្រោះកូនក្តីខ្ញុំមិនបានកាន់កាបូបរបស់ជនរងគ្រោះ ។ ចំណែករូបថតគឺចេញពីហ្វេសប៊ុកគឺគេអាចកាត់តធ្វើអ្វីក៏បានដែរ ហើយរូបភាពនេះមិនមែនចេញពីប៉ូលីសទេ គឺចេញពីហ្វេសប៊ុក មានសាក្សីឈ្មោះ [redacted] ម៉ាឡា ប្រាប់ថា ឈ្មោះ [redacted] ចិន្តា មិនមែនកូនក្តីខ្ញុំវាយដំទេ រីឯភស្តុតាងគឺជនរងគ្រោះជាអ្នករៀបចំដោយខ្លួនឯង ។

ចំណែករូបភាពអាសអាភាស ខ្ញុំសុំចៅក្រមមើលឃើញរូប១ សែលហ្វីអាក្រាតក្នុងវីដេអូ គឺកូនក្តីខ្ញុំអត់បានដឹងទេ ព្រោះរូបនេះគ្មានភស្តុតាងចេញពីប្រភពជាក់លាក់គឺមានការសែរត១គ្នា ព្រោះកូនក្តីខ្ញុំកំពុងរៀននៅប្រទេសវៀតណាម ខែឧសភា ឆ្នាំ២០១៦ ។

សំណូមពរ ៖ សុំឯកឧត្តម និងក្រុមប្រឹក្សា មេត្តាលើកលែងកូនក្តីខ្ញុំឱ្យរួចផុតពីបទចោទ ។

Scanned with CamScanner

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ និងសេចក្ដីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

១-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ៤៥២ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សិទ្ធិសក្ដិ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ មាត្រា ៤១៧ មាត្រា ៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ភ្នំពេញ សម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចប្រកាសពិរុទ្ធភាព និងផ្ដន្ទាទោស លើជនជាប់ចោទឈ្មោះ [redacted] សិទ្ធិសក្ដិ ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ ពីបទ ហិង្សាដោយចេតនា និងបទចែកចាយរូបភាពអាសអាភាស ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៦ តាមមាត្រា ២១៧ និងមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ មាត្រា ៣៨ និងមាត្រា ៣៩ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនោះ មិនមានមូលដ្ឋានគ្រប់គ្រាន់នៅឡើយទេ ព្រោះថា ជនជាប់ចោទឈ្មោះ [redacted] សិទ្ធិសក្ដិ មិនទទួលស្គាល់នូវអំពើដែលបានចោទប្រកាន់នោះទេ ហើយភស្ដុតាងដាក់បន្ទុកលើជនជាប់ចោទ បានផ្អែកទៅលើភាពស៊ីសង្វាក់គ្នានៃចម្លើយរបស់ជនរងគ្រោះ និងសាក្សីដែលមិនបានឃើញហេតុការណ៍ មិនមានការបញ្ជាក់ដោយភស្ដុតាងច្បាស់លាស់ និងបានផ្អែកទៅលើខែ្សបថត និងរូបភាព អក្សរ ដែលព្រីនចេញពីឧបករណ៍អេឡិចត្រូនិច ដែលត្រូវបានបញ្ជូនពីមន្ត្រីនគរបាលយុត្តិធម៌មកឱ្យប៉ុណ្ណោះ ប៉ុន្តែមិនមានបញ្ជាក់បង្ហាញអំពីនីតិវិធីបញ្ជូន និងការទទួលយកភស្ដុតាងនេះតាមវិធីណា ហើយក៏មិនមានការស្វែងរកឱ្យឃើញម្ចាស់គណនីរបស់សារដែលបានបង្ហោះចេញនោះដែរ ។ ដូច្នេះ ការស៊ើបសួរក្នុងរឿងក្ដីនេះ នៅខ្វះខាតមិនទាន់មានលក្ខណៈពេញលេញ ដែលគប្បីស៊ើបសួរបន្ថែមឃើញថា បណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ មានមូលហេតុត្រឹមត្រូវតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១០២ ក្រ.IIIប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ មិនត្រឹមត្រូវតាមគតិច្បាប់ ។

**ហេតុដូច្នេះ**

**សម្រេច**

១.ទទួល បណ្ដឹងសាទុក្ខលេខ ៤៥២ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សិទ្ធិសក្ដិ ។

Scanned with CamScanner

២.បដិសេធ សាលដីកាព្រហ្មទណ្ឌលេខ ១០២ ក្រ.ប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ទាំងមូល ។

៣.បញ្ជូន សំណុំរឿងព្រហ្មទណ្ឌលេខ ៤០ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីធ្វើការស៊ើបសួរ និងជំនុំជម្រះជាថ្មី ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ ។

Scanned with CamScanner